ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

២០/៤

សាលាដំបូងខេត្តពោធិសាត់

បញ្ជីក្តីលេខ ៨៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១

ឈ្មោះរឿងក្តីៈ វិវាទកិច្ចសន្យា

សាលក្រមរដ្ឋប្បវេណីលេខ១១៦ (៧) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១

កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១

## សាលក្រមរដ្ឋប្បវេណី

សាលាដំបូងខេត្តពោធិសាត់

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

-លោ[redacted] ចៅក្រមសាលាដំបូងខេត្តពោធិសាត់

**ក្រឡាបញ្ជីសវនាការ**

-លោក[redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិសាត់

ក្រោយពីបានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ រវាង :

**-ដើមចោទឈ្មោះ**[redacted] ឆោម ភេទប្រុស អាយុ៨៣ឆ្នាំ មុខរបររកស៊ីរកលក់ដូរ ទីលំនៅបច្ចុប្បន្ននៅភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិសាត់ ប្រពន្ធឈ្មោះ[redacted] ឃឹម មានកូន០៥នាក់។

**-ចុងចម្លើយឈ្មោះ**[redacted] ទី ភេទស្រី អាយុ៣៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិស្ពានមាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ប្តីឈ្មោះ[redacted] **ឃីវ** មានកូន០៤នាក់ និង**ចុងចម្លើយឈ្មោះ** [redacted] ធុន ភេទស្រី អាយុ៦៣ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិកោះស្វាយ ឃុំខ្នាទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ប្តីឈ្មោះ [redacted] ធួក មានកូនចំនួន០៦នាក់ ។

**-កម្មវត្ថុបណ្តឹង:** សុំសាលក្រម:

-បញ្ឈប់ការជួលដីស្រែទំហំ៦(ប្រាំមួយ)ហិកតា ពីចុងចម្លើយ។

-បង្គាប់ឲ្យចុងចម្លើយប្រគល់ដីស្រែទាំង៦(ប្រាំមួយ)ហិកតា ។



២៣៦

236

Scanned with CamScanner

-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ជំពាក់ និងឈ្នួលស្រែសរុបចំនួន ១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំរយពាន់) ។

## អង្គហេតុនិងចំណុចវិវាទ

កាលពីក្នុងអំឡុងឆ្នាំ២០០៣ ចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យីវ ប្រពន្ធឈ្មោះ [redacted] ទី ដែលជាក្រុមគ្រួសារឪពុកម្ដាយនិងកូន បានខ្ចីប្រាក់របស់ឈ្មោះ [redacted] ឆោម ជាដើមចោទដើម្បីយកទៅរកស៊ីជួញដូរសត្វគោក្របីទៅប្រទេសវៀតណាម ដោយការរកស៊ីខាតបង់មិនអាចរកប្រាក់សងបំណុលទៅឲ្យដើមចោទវិញ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ ចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី បានលក់ដីស្រែទំហំ២០០០០(ពីរម៉ឺន)ម៉ែត្រការ៉េ តម្លៃ៤.០០០.០០០(បួនលាន)រៀល មកឲ្យដើមចោទឈ្មោះ [redacted] ឆោម (មានឯកសារបញ្ជាក់) និងក្រោយមកទៀតនៅក្នុងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ចុងចម្លើយឈ្មោះ [redacted] ធួក និងប្រពន្ធឈ្មោះ [redacted] ធុន ត្រូវជាឪពុកម្ដាយបង្កើតរបស់ចុងចម្លើយឈ្មោះ [redacted] យីវ បានលក់ដីស្រែទំហំ ៤០០០០(បួនម៉ឺន)ម៉ែត្រការេ មកឲ្យដើមចោទឈ្មោះ [redacted] ឆោម ទៀត (មានឯកសារបញ្ជាក់) ដើម្បីកាត់ប្រាក់ជំពាក់ ។ ក្រោយពីទិញរួច ដើមចោទបានជួលដីស្រែទាំងពីរកន្លែងនោះ ទៅឲ្យចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី ធ្វើស្រែទាំង៦(ប្រាំមួយ)ហិកតា ដោយយកឈ្នួលក្នុងមួយហិកតាជាស្រូវទម្ងន់៤០០គីឡូក្រាម (មានឯកសារបញ្ជាក់) ។ ចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី បានឲ្យឈ្នួលស្រែជារៀងរាល់ឆ្នាំ លើកលែងតែនៅក្នុងឆ្នាំ២០១០ ចុងចម្លើយនៅខ្វះឈ្នួលស្រែចំនួន២.០០០.០០០(ពីរលាន)រៀល បន្ទាប់មកថាឈប់ឲ្យឈ្នួលនៅឆ្នាំបន្តទៀតមកឲ្យដើមចោទ ដោយអះអាងថាមិនប្រគល់ដីស្រែនោះមកឲ្យដើមចោទទេ ព្រោះខ្លួនមិនបានលក់ឲ្យដើមចោទ ។ ក្រោយពីលក់ដីរួចចុងចម្លើយនៅជំពាក់បំណុលដើមចោទដែលបានខ្ចីមួយចំនួនទៀត ដើមចោទទាមទារឲ្យចុងចម្លើយសងប្រាក់ជំពាក់សរុបទាំងប្រាក់ខ្ចី និងប្រាក់ឈ្នួលស្រែចំនួន ១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំរយពាន់)រៀល ដែលចុងចម្លើយមិនទាន់បានសង ។

-តាមចម្លើយឈ្មោះ [redacted] ឆោម ជាដើមចោទ បានបញ្ជាក់ថា ខ្លួនប្ដឹងសុំឲ្យតុលាការសម្រេចឲ្យចុងចម្លើយប្រគល់ដីស្រែចំនួន៦(ប្រាំមួយ)ហិកតា ស្ថិតនៅភូមិស្នាលមាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដូចក្នុងកិច្ចសន្យាលក់ផ្ដាច់ដី និងលិខិតបញ្ជាក់ទីតាំងដីទំនាស់ របស់មេភូមិស្នាលមាន់ និងមេឃុំតាលោ មកឲ្យខ្លួន និងសម្រេចបង្គាប់ឲ្យចុងចម្លើយសងបំណុល និងប្រាក់ឈ្នួលស្រែសរុបទាំងអស់ ចំនួន១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំសែន)រៀល មកឲ្យខ្លួនវិញ ដោយមូលហេតុថា ដីនោះចុងចម្លើយបានលក់ផ្ដាច់ឲ្យខ្លួនរួចហើយ និងបានជួលពីខ្លួនទៅធ្វើស្រែវិញ ដោយមានលិខិតស្នាមច្បាស់លាស់ ស្រាប់តែពេលនេះចុងចម្លើយមិនប្រគល់ដីស្រែ និងប្រាក់ឈ្នួលស្រែមកឲ្យខ្លួនវិញ ទើបខ្លួនប្ដឹងមកតុលាការនេះ ។ —

-តាមការអះអាងតបរបស់ចុងចម្លើយឈ្មោះ [redacted] ទី ជាប្រពន្ធរបស់ឈ្មោះ [redacted] យីវ បញ្ជាក់ថា នៅពេលនេះ ខ្លួនទទួលស្គាល់ថា នៅជំពាក់បំណុលដើមចោទសរុបចំនួន១៩.០០០.០០០(ដប់ប្រាំបួនលាន)រៀល តែខ្លួនមិន

ទទួលស្គាល់ថាបានលក់ផ្តាច់ដីឲ្យទៅដើមចោទ និងធ្វើលិខិតជួលដីមកវិញនោះទេ គឺខ្លួនគ្រាន់តែបានដាក់ដីនោះបញ្ចាំ ដើម្បីធានាបំណុលតែប៉ុណ្ណោះ ដោយសន្យាថារយៈពេល៣(បី)ឆ្នាំលួសយកដីវិញ លុះគំរប់៣(បី)ឆ្នាំ ដើមចោទមិនឲ្យខ្លួនសងបំណុលលួសយកដីវិញ ដោយអះអាងថាដីនោះខ្លួនលក់ផ្តាច់រួចហើយ មិនអាចលួសបានទេ ។ តាមពិតខ្លួនបានផ្តិតមេដៃលើកិច្ចសន្យាមែន តែខ្លួនមិនចេះអក្សរទើបមិនដឹងថាជាកិច្ចសន្យាលក់ផ្តាច់ដីឲ្យទៅដើមចោទ ។

-តាមការអះអាងតបរបស់ចុងចម្លើយឈ្មោះ [redacted] ធុន ជាប្រពន្ធរបស់ឈ្មោះ [redacted] ធួក បានបញ្ជាក់ថា: ខ្លួនមិនប្រគល់ដីឲ្យដើមចោទតាមការទាមទាររបស់ដើមចោទនោះទេ ព្រោះខ្លួនមិនបានលក់ តាមពិតខ្លួនបានផ្តិតមេដៃឲ្យទៅដើមចោទមែន តែផ្តិតមេដៃដាក់បញ្ចាំធានាបំណុលប៉ុណ្ណោះ ដោយសារខ្លួនមិនចេះអក្សរទើបមានរឿងដូចនេះ ។

-តាមការអះអាងតបវិញរបស់ដើមចោទឈ្មោះ [redacted] ឆោម បានបញ្ជាក់ថា: មុនដំបូងភាគីចុងចម្លើយបានខ្ចីប្រាក់ពីខ្លួនយកទៅរកស៊ី តែក្រោយមកគ្មានប្រាក់សងវិញទើបលក់ដីដើម្បីកាត់បំណុលជំពាក់ តាមតម្លៃដីទីផ្សារ ដោយភាគីចុងចម្លើយជាអ្នករត់ការចុះហត្ថលេខាភូមិឃុំដោយខ្លួនឯងទៀតផង ។ ដើមចោទបញ្ជាក់ថា ចំពោះរឿងមិនចេះអក្សនោះគឺមិនពិតទេ រាល់ពេលខ្ចីប្រាក់ពីខ្លួនម្តងៗតែងតែមានការសសេរលិខិតផ្ទាល់ដៃរបស់ឈ្មោះ [redacted] ធួក ទើបខ្លួនហ៊ានប្រគល់ប្រាក់ឲ្យ មានដូចឯកសារភស្តុតាងដាក់ជូនតុលាការពិនិត្យស្រាប់ ។

-ចុងចម្លើយឈ្មោះ [redacted] ធុន បានអះអាងតបដោយបញ្ជាក់ក្នុងអង្គសវនាការថា នៅពេលនេះប្តីខ្លួនឈ្មោះ [redacted] ធួក មានជម្ងឺមិនអាចមកចូលរួមនាពេលនេះបាន ខ្លួនសុំលើកពេលទាញហេតុផលផ្ទាល់មាត់នេះទៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨ព្រឹក ដើម្បីឲ្យប្តីរបស់ខ្លួនឈ្មោះ [redacted] ធួក ឆ្លើយអះអាងជូនតុលាការឲ្យបានច្បាស់លាស់ក្នុងរឿងនេះ ។

នីតិវិធីទាញហេតុផលផ្ទាល់មាត់ ត្រូវបានលើពេលទៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ តាមការសុំរបស់ចុងចម្លើយឈ្មោះ [redacted] ធុន ។

-នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨ព្រឹក នីតិវិធីទាញហេតុផលផ្ទាល់មាត់ត្រូវបានបន្ត ឈ្មោះ [redacted] ធួក ជាចុងចម្លើយបានអះអាងដោយបញ្ជាក់ថា ខ្លួនធ្លាប់បានខ្ចីប្រាក់ពីដើមចោទឲ្យកូនយកទៅរកស៊ីមែន ដោយបានសងវិញខ្លះរួចហើយ នៅជំពាក់ខ្លះមិនទាន់មានប្រាក់សងទើបទៅវាស់ដីស្រែដាក់បញ្ចាំ ។ តែពេលបំពេញលិខិតដាក់បញ្ចាំ បានធ្វើជាលិខិតលក់ផ្តាច់ទៅវិញ ពេលនោះខាងខ្លួនបានតវ៉ាដែរ តែដើមចោទថាជួលជាធ្វើដូចនោះរួចហើយធ្វើតាមលិខិតនោះចុះ តែរឿងពិតជាក់ស្តែងគឺគ្រាន់តែដាក់បញ្ចាំទេ ។ ការដាក់បញ្ចាំនោះ គឺនៅឆ្នាំ២០០៣ ចំនួន២(ពីរ)ហិកតាបញ្ចាំប្រាក់ដើម៤.០០០.០០០(បួនលាន)រៀល ដោយគិតការប្រាក់ជាផលស្រូវ ១(មួយ)ហិកតាម្នាក់ រីឯដី៤(បួន)ហិកតាទៀត ដាក់បញ្ចាំនៅឆ្នាំ២០០៦ ប្រាក់ដើម១៥.០០០.០០០(ដប់ប្រាំលាន)រៀល គិតការប្រាក់ជាផលស្រូវក្នុង១(មួយ)ហិកតា៨០០(ប្រាំបួនរយ)គីឡូក្រាម ។ ឈ្មោះ [redacted] ធួក បានបញ្ជាក់បន្តថា ក្នុងពេលព្រមព្រាងថាដាក់បញ្ចាំនោះដែរ ដើមចោទបានឲ្យផ្តិតមេដៃលើលិខិតជួលស្រែមួយទៀត ដោយមិនឲ្យគាត់អាន និង

២៣៥

ជឿទុកចិត្តគ្នា ពួកខ្លួនក៏ផ្តិតមេដៃឲ្យទៀត ដោយសន្យាគ្នាថារយៈពេល៣(បី)ឆ្នាំលួសយកដីវិញ ។ លុះគ្រប់៣(បី)ឆ្នាំ ខ្លួនបានសុំសងប្រាក់លួសយកដីវិញ ស្រាប់តែដើមចោទប្រកាន់យកតាមកិច្ចសន្យាលក់ដី និងកិច្ចសន្យាជួលស្រែនោះទៅវិញ ទើបមានរឿងដូចនេះមកតុលាការ ។ ឈ្មោះ [redacted] ធួក បានបញ្ជាក់ថា ខ្លួនមិនប្រគល់ដីឲ្យដើមចោទតាមលិខិតទិញលក់នោះទេ ខ្លួនសុំសងប្រាក់ជំពាក់សរុបចំនួន ១៩.០០០.០០០(ដប់ប្រាំបួនលាន)រៀល ទៅដើមចោទវិញជាដំណាក់ៗ ក្នុងរយៈពេល២(ពីរ)ឆ្នាំទៀតឲ្យរួចបំណុលទាំងអស់ ។

-ដើមចោទឈ្មោះ [redacted] ឆោម បានអះអាងតបថា : មុនពេលលក់ដីផ្តាច់ឲ្យខ្លួននោះ ចុងចម្លើយធ្លាប់ខ្ចីប្រាក់ពីខ្លួនជាច្រើនលើកច្រើនសារ និងពេលខ្លះធ្លាប់ដាក់បញ្ចាំដីមែន ដោយមានទម្រង់លិខិតដាក់បញ្ចាំផ្សេងពីលិខិតលក់ផ្តាច់នេះ ខ្លួនបានជូនតុលាការជាភស្តុតាងរួចហើយ ។ ចំពោះការលក់ទិញដី គឺលក់ទិញតាមហាងឆេងដីនាពេលនោះដែរ បើដាក់បញ្ចាំគេមិនដែលបញ្ចាំស្មើនឹងតម្លៃដីដូចនោះទេ ។[redacted] ឆោម បញ្ជាក់ទៀតថា ចុងចម្លើយមិនត្រឹមតែលក់ដីនោះឲ្យខ្លួនទេ ថែមទាំងចុះកិច្ចសន្យាជួលដីពីខ្លួនទៀត ដូចមានភស្តុតាងជូនតុលាការពិនិត្យរួចហើយ ។ ក្នុងរឿងនេះ ខ្លួននៅតែតាមទារសុំឲ្យតុលាការសម្រេចឲ្យចុងចម្លើយប្រគល់ដីស្រែចំនួន៦(ប្រាំមួយ)ហិកតា និងសម្រេចបង្គាប់ឲ្យចុងចម្លើយសងបំណុល និងប្រាក់ឈ្នួលស្រែសរុបទាំងអស់ចំនួន១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំសែន)រៀល មកឲ្យខ្លួនវិញដដែល ។

-នៅពេលសួរបញ្ជាក់រកភស្តុតាង ដែលបញ្ជាក់ថាមិនបានលក់ដីឲ្យដើមចោទ និងមិនបានជួលស្រែពីដើមចោទ ចុងចម្លើយបានឆ្លើយដូចៗគ្នាថា ពុំមានឯកសារភស្តុតាងឬសាក្សីមកបញ្ជាក់ទេព្រោះមិនបានធ្វើ ដោយខ្លួននិងដើមចោទបានសន្យាគ្នាតែផ្ទាល់មាត់ប៉ុណ្ណោះ ។ ចុងចម្លើយបានសំណូមពរដូចៗគ្នាថា មិនប្រគល់ដីស្រែទៅឲ្យដើមចោទតាមការទាមទារទេ ខ្លួនសុំសងប្រាក់ជំពាក់និងប្រាក់ឈ្នួលស្រែសរុបចំនួន ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ទៅឲ្យដើមចោទវិញ ក្នុងអំឡុងពេល២(ពីរ)ឆ្នាំទៀត ។

## សំអាងហេតុ

១-តុលាការយល់ថា ដើមចោទឈ្មោះ [redacted] ឆោម ប្តឹងទាមទារបញ្ឈប់ការជួលដីស្រែពីចុងចម្លើយឈ្មោះ [redacted] យើវ និងប្រពន្ធឈ្មោះ[redacted] ទី និងចុងចម្លើយឈ្មោះ[redacted] ធួក និងប្រពន្ធ ឈ្មោះ[redacted] ធុន ព្រមទាំងទាមទារឲ្យចុងចម្លើយគ្រប់ដីស្រែដែលបានជួល និងទាមទារឲ្យចុងចម្លើយសងប្រាក់ឈ្នួលស្រែនិងប្រាក់កំចីសរុបចំនួន ១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំរយពាន់) ដោយសំអាងលើឯកសារភស្តុតាងកិច្ចសន្យាលក់ផ្តាច់ដី និងកិច្ចសន្យាជួលស្រែ ចំណុចនេះតុលាការអាចពិចារណាតាមច្បាប់បាន ។

២-តុលាការយល់ថា ចុងចម្លើយឈ្មោះ [redacted] យើវ ប្រពន្ធឈ្មោះ [redacted] ទី និងចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ[redacted] ធុន មិនទទួលស្គាល់ការទាមទាររបស់ដើមចោទដោយអះអាងថា ពួកខ្លួនមិនបានលក់ដីស្រែឲ្យដើមចោទទេ គឺខ្លួនគ្រាន់តែបានដាក់បញ្ចាំដីស្រែជាមួយដើមចោទ ដោយខ្លួនមិនមានឯកសារបញ្ជាក់នោះទេ ចំណុចនេះតុលាការមិនអាចពិចារណាទៅលើការមិនទទួលស្គាល់ការទាមនោះបានឡើយ ។



៦៣៩

៣-តុលាការយល់ថា ការអះអាងចំពោះការទាមទាររបស់ដើមចោទអំពីការលក់ទិញ និងជួលដីស្រែរវាងខ្លួន និងចុងចម្លើយ ដោយសំអាងលើកិច្ចសន្យាលក់ផ្តាច់ដីចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ រវាងខ្លួន និងចុងចម្លើយឈ្មោះ [redacted] យីវ ប្រពន្ធឈ្មោះ [redacted] ទី និងកិច្ចសន្យាលក់ផ្តាច់ដីចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៣ រវាងខ្លួន និងចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន ព្រមទាំងកិច្ចសន្យាជួលស្រែចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ដែលសុទ្ធតែមានស្នាមមេដៃរបស់គូភាគី និងមានការបញ្ជាក់របស់អាជ្ញាធរភូមិឃុំផងនោះ តុលាការអាចពិចារណាតាមច្បាប់បាន ។

៤-តុលាការយល់ថា ភាគីដើមចោទប្រកាន់យកកិច្ចសន្យាលក់ រីឯភាគីចុងចម្លើយប្រកាន់យកកិច្ចសន្យាធានាបំណុល គឺបញ្ចាំដីស្រែ ដែលចំណុចនេះគឺជាចំណុចវិវាទរបស់គូភាគី ។ ចំណុចវិវាទមួយទៀតគឺ ចំនួនទឹកប្រាក់ជំពាក់ដើមចោទ ដើមចោទថា១៧.៥០០.០០០(ដប់ប្រាំពីរលានប្រាំសែន)រៀល រីឯចុងចម្លើយទទួលស្គាល់បំណុលរហូតដល់២៥.០០០.០០០(ម្ភៃប្រាំ)រៀលឯណោះ ។

៥-តុលាការយល់ថា ភាគីចុងចម្លើយបានទទួលស្គាល់ប្រាក់ជំពាក់ដើមចោទពិតមែន ប៉ុន្តែខ្លួនមិនច្បាស់គ្រប់ជ្រុងជ្រោយទេ រីឯកិច្ចសន្យាលក់ដីចុងចម្លើយមិនទទួលស្គាល់ឡើយ ប៉ុន្តែចុងចម្លើយបានធ្វើការតវ៉ាតែមាត់ទទេ ពុំមានឯកសារដាក់មកតុលាការឡើយ ដែលចំណុចនេះតុលាការយល់ថា ចុងចម្លើយបានសារភាពអំពីអង្គហេតុនោះហើយ ហើយដែលចំណុចនេះ តុលាការអាចពិចារណាបានតាមមាត្រា៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៧-តុលាការយល់ថា តាមការពិនិត្យលើកិច្ចសន្យា ដែលភាគីដើមចោទដាក់មកឲ្យតុលាការ គឺមានតែកិច្ចសន្យាលក់ផ្តាច់ និងកិច្ចសន្យាជួលស្រែ រីឯឯកសារដែលតវ៉ាដោយភាគីចុងចម្លើយ ពុំមានដាក់មកតុលាការទេ ។

៨-តុលាការយល់ថា តាមការផ្ទៀងផ្ទាត់លិខិតរបស់ [redacted] ធួក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៤ ដែលសរសេរផ្ទាល់ដៃរបស់ [redacted] ធួក បានបញ្ជាក់ថា កូនបំណុល [redacted] ធួក ពិតជាបានធ្លាប់ខ្ចីប្រាក់ពីម្ចាស់បំណុលឈ្មោះ [redacted] ឆោម ប្រាកដមែន ប៉ុន្តែដោយខ្លួនខ្វះខាតមិនមានប្រាក់សងបំណុលវិញ ទើបយកដីស្រែទៅទូទាត់បំណុលជាមួយ [redacted] ឆោម ទើបធ្វើឲ្យមានកិច្ចសន្យាលក់ដីផ្តាច់ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ និងកិច្ចសន្យាលក់ដីផ្តាច់ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ នោះឡើង ។ ហើយម្ចាស់បំណុលក៏ជួលដីនោះទៅឲ្យ [redacted] .យីវ រហូតមកដល់បច្ចុប្បន្ននេះ ។ ចំណុចទាំងអស់នេះតុលាករយល់ថា ពិតជាដើមចោទ [redacted] ឆោម ជួលដីស្រែទាំង៦(ប្រាំមួយ)ហិកតាដែលបានទិញទៅឲ្យ [redacted] យីវ ប្រាកដមែន តាមកិច្ចសន្យាជួលស្រែចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ គឺពុំដូចការអះអាងរបស់ចុងចម្លើយ [redacted] ធួក ដែលថាខ្លួនដាក់ធានាបំណុលនោះទេ ចំណុចនេះ តុលាការមិនអាចពិចារណាទៅតាមមាត្រា២១៩,២២០,២២១ នៃច្បាប់ភូមិបាលនោះបានឡើយ ។

៩-តុលាការយល់ថា ចុងចម្លើយទាំងពីរគឺជាឪពុកម្តាយនិងកូន តាមកិច្ចសន្យាលក់ផ្តាច់ដីចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ ចុងចម្លើយ [redacted] យីវ និង ប្រពន្ធឈ្មោះ [redacted] ទី បានលក់ដីស្រែទំហំ២០០០០(ពីរម៉ឺន) ម៉ែត្រការ៉េ នៅភូមិស្គាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់

-ខាងជើងទល់នឹងដីឈ្មោះ [redacted]សឿន

-ខាងត្បូងទល់នឹងឈ្មោះ គ្រួន

-ខាងកើតទល់នឹងដីឈ្មោះ ពូខុល

-ខាងលិចទល់នឹងដីឈ្មោះ [redacted] ធួក ទៅឲ្យដើមចោទឈ្មោះ [redacted] ឆោម និងតាមកិច្ចសន្យាលក់ផ្ដាច់ដីចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៦ ចុងចម្លើយ[redacted] ធួក និង ប្រពន្ធឈ្មោះ [redacted] ធុន បានលក់ដីស្រែទំហំ៤០០០០(បួនម៉ឺន)ម៉ែត្រការ៉េ នៅភូមិស្គាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់ :

-ខាងជើងទល់នឹងឈ្មោះ ណូម

-ខាងត្បូងទល់នឹងផ្លូវរទេះ

-ខាងកើតទល់នឹងដីឈ្មោះ តាភឿន

-ខាងលិចទល់នឹងផ្លូវ ទៅឲ្យដើមចោទឈ្មោះ[redacted] ឆោម ។ ក្រោយពីទិញរួច ចុងចម្លើយឈ្មោះ[redacted] យីវ បានជួលដីស្រែដែលបានលក់ ទាំងពីរកិច្ចសន្យាខាងលើមកធ្វើស្រែវិញ តាមកិច្ចសន្យាជួលស្រែ ចុះថ្ងៃ ទី០៦ ខែមិថុនា ឆ្នាំ២០០៧ ចំណុចទាំងនេះតុលាការអាចពិចារណាតាមច្បាប់បាន ។

១០-តុលាការយល់ថា កិច្ចសន្យាគឺជាច្បាប់របស់គូភាគី ហើយការដោះសាររបស់ភាគីចុងចម្លើយ ពុំមានទឡ្ហីករណ៍ត្រឹមត្រូវឡើយ គឺអះអាងតែមាត់ទទេ ពុំមានហេតុផលដែលអាចឲ្យតុលាការជឿបាន ។ ចំពោះចំនួនទឹកប្រាក់ភាគីចុងចម្លើយថាជំពាក់សរុបរហូតដល់២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល រីឯដើមចោទថាជំពាក់តែចំនួន១៧.៥០០.០០០(ដប់ប្រាំពីរលានប្រាំសែន)រៀលប៉ុណ្ណោះ ដែលការផ្ទុយគ្នាទៅលើចំនួននេះ តុលាការគួរពិចារណាទៅលើចំនួនទឹកប្រាក់ដែលភាគីដើមចោទទាមទារ ។

ហេតុដូច្នេះសាលាដំបូងខេត្តពោធិសាត់

**វិនិច្ឆ័យសេចក្ដី**

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១១ និងទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] ឆោម ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ក/-បង្គាប់ឲ្យឈ្មោះ [redacted] ធួក និងប្រពន្ធឈ្មោះ [redacted] ធុន ប្រគល់ដីស្រែទំហំ៤០០០០(បួនម៉ឺន)ម៉ែត្រការ៉េ នៅភូមិស្គាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់ :

-ខាងជើងទល់នឹងឈ្មោះ ណូម

-ខាងត្បូងទល់នឹងផ្លូវរទេះ

-ខាងកើតទល់នឹងដីឈ្មោះ តាភឿន

-ខាងលិចទល់នឹងថ្នល់ ទៅឲ្យដើមចោទឈ្មោះ [redacted] ឆោម ។ ៧/

ខ/-បង្គាប់ឲ្យឈ្មោះ [redacted] យឺវ និងប្រពន្ធឈ្មោះ [redacted] ទី ប្រគល់ដីស្រែទំហំ២០០០០(ពីរម៉ឺន)ម៉ែត្រការ៉េ នៅភូមិស្គាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់ :

-ខាងជើងទល់នឹងដីឈ្មោះ មីងសឿន

-ខាងត្បូងទល់នឹងឈ្មោះ គ្រូវន

-ខាងកើតទល់នឹងដីឈ្មោះ ពូឌុល

-ខាងលិចទល់នឹងដីឈ្មោះ [redacted] ធួក ទៅឲ្យដើមចោទឈ្មោះ [redacted] ឆោម ។

គ/-បង្គាប់ឲ្យឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យឺវ ប្រពន្ធឈ្មោះ [redacted] ទី រួមគ្នាសងប្រាក់ដំពាក់ និងប្រាក់ឈ្នួលស្រែសរុបចំនួន១៧.៥០០.០០០(ដប់ប្រាំពីរលានប្រាំសែន)រៀល ទៅឲ្យឈ្មោះ [redacted] ឆោម ជាម្ចាស់បំណុល ។

៣-ច្រានចោលការទាមទាររបស់ភាគីចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យឺវ ប្រពន្ធឈ្មោះ [redacted] ទី ដែលសុំឲ្យដើមចោទប្រគល់ដីស្រែឲ្យខ្លួនវិញ ដោយសុំសងបំណុលទៅដើមចោទចំនួន ២៥(ម្ភៃប្រាំលាន)រៀលវិញក្នុងរយៈពេល២(ពីរ)ឆ្នាំទៀត ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៥-សាលក្រមនេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១១ ចំពោះមុខដើមចោទ និងចុងចម្លើយ ។

បើកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ចៅក្រមជំនុំជម្រះ

[redacted]